**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ០៧/១៦ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៦

# សេចក្តីណែនាំ
# ស្តីពី
# តួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន

**យោង**: - ជំពូកទី V នៃលក្ខន្តិកៈ និងជំពូកទី IX នៃបទបញ្ជាផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា ។

- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្ស ក្នុងដំណាក់កាលបច្ចុប្បន្ន ។

- មតិឯកភាពរបស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៦ ។

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន ដូចខាងក្រោម :

## I- <u>តួនាទី ភារកិច្ច សិទ្ធិ របស់គណៈកម្មាធិការគណបក្សមូលដ្ឋាន</u>

### ក- <u>អំពីតួនាទី ភារកិច្ច</u> :

គណៈកម្មាធិការគណបក្សមូលដ្ឋាន ជាអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស ដែលត្រូវបានបង្កើតឡើងនៅតាមឃុំ សង្កាត់ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម រោងចក្រ សហគ្រាស អង្គការសង្គមនានា មន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត អគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួង ស្ថាប័ន ។

គណៈកម្មាធិការគណបក្សមូលដ្ឋាន ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការគណបក្សថ្នាក់លើ និងថ្នាក់ខ្លួន ក្នុងការដឹកនាំត្រួតពិនិត្យការអនុវត្តគ្រប់វិស័យការងាររបស់គណបក្ស ដើម្បីសម្រេចភារកិច្ចនយោបាយដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសម្រេចចិត្តរបស់គណបក្សថ្នាក់ខ្លួន ។

គណៈកម្មាធិការគណបក្សមូលដ្ឋានមានភារកិច្ច :

១- ក្តាប់ជាប់កម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍នានារបស់គណបក្ស និងសេចក្តីសម្រេចផ្សេងៗរបស់គណបក្សថ្នាក់លើ ហើយកសាងទិសដៅ និងផែនការចាត់តាំងអនុវត្តឲ្យបានសមស្របនឹងសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាន ។

២- យកចិត្តទុកដាក់អប់រំសមាជិកគណបក្ស មហាជន ប្រជាជនឲ្យបានយល់ជ្រួតជ្រាបច្បាស់អំពីកម្មវិធីនយោបាយ គោលការណ៍ សេចក្តីសម្រេច ឯកសារផ្សេងៗទៀតរបស់គណបក្ស សភាពការណ៍ និងសមិទ្ធផលនានាដែលគណបក្សបានសម្រេចជូនជាតិ ដើម្បីលើកកម្ពស់ស្មារតីភ្ញាក់រលឹករបស់សមាជិកគណបក្ស និងខិតខំចលនាមហាជន ប្រជាជន គាំទ្រ និងចូលរួមអនុវត្តនូវកម្មវិធីនយោបាយរបស់គណបក្សដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា និងជោគជ័យរបស់គណបក្សក្នុងការបោះឆ្នោត ។

៣- ពង្រឹងពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស ផ្សារភ្ជាប់ជិតស្និទ្ធជាមួយសមាជិកគណបក្ស មហាជន ប្រជាជន និងមានទំនាក់ទំនងសហការជាមួយអាជ្ញាធរដែនដី អង្គការសង្គម អង្គភាពផលិតកម្ម អង្គភាពជំនាញនៅមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមចំណែកលើកកម្ពស់ឥទ្ធិពលរបស់គណបក្សក្នុងការអភិវឌ្ឍមូលដ្ឋាន ។

៤- បែងចែកភារកិច្ចទទួលខុសត្រូវ និងត្រួតពិនិត្យការងារគ្រប់គ្រងសមាជិកគណបក្ស ការងារពង្រីកសមាជិកថ្មី និងការអនុវត្តរបបប្រជុំជីវភាពគណបក្សឲ្យបានទៀងទាត់ ព្រមទាំងបំផុសស្មារតីភ្ញាក់រលឹកបង់វិភាគទានប្រចាំខែស្របតាមការកំណត់របស់លក្ខន្តិកៈគណបក្ស ។

៥- លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នការពារជួរមន្ត្រីគណបក្ស រក្សាការសម្ងាត់របស់គណបក្សទប់ស្កាត់នូវការជ្រៀតចូលនៃសមាសភាពឱកាសនិយមដើម្បីបំផ្លាញគណបក្ស ។ បកអាក្រាតទាន់ពេលវេលានូវរាល់ល្បិចកល និងការឃោសនាមួលបង្កាច់ដែលធ្វើឲ្យខូចកិត្យានុភាពរបស់គណបក្ស ។

៦- លើកកម្ពស់ស្មារតីម្ចាស់ការក្នុងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិហិរញ្ញវត្ថុរបស់គណបក្សនៅមូលដ្ឋានរបស់ខ្លួនឲ្យបានម៉ត់ចត់ និងអនុវត្តគោលការណ៍សន្សំសំចៃ ។

គ- **<u>អំពីសិទ្ធិ</u>** :

គណៈកម្មាធិការគណបក្សមូលដ្ឋានមានសិទ្ធិ :

១- សម្រេចយល់ព្រមបញ្ចូលសមាជិកថ្មី សម្រេចបង្កើតអនុសាខាគណបក្ស និងក្រុមបក្សចំណុះ ។

២- សម្រេចការលើកសរសើរ និងដាក់វិន័យចំពោះអនុសាខា ក្រុមបក្ស និងសមាជិកគណបក្ស ។

៣- កោះអញ្ជើញមន្ត្រីសមាជិកគណបក្សចូលរួមប្រជុំជីវភាពបក្សតាមការកំណត់ និងចូលរួមសកម្មភាពនានារបស់គណបក្សនៅមូលដ្ឋាន ។

៤- ក្រើនរំលឹក ដាស់តឿន និងណែនាំការងារគណបក្សដល់គណៈកម្មាធិការសាខាគណបក្ស អនុសាខា និងក្រុមបក្សចំណុះ ។

៥- លើកសំណើជូនគណៈកម្មាធិការគណបក្សថ្នាក់លើពិនិត្យ សម្រេចនូវការងារមួយចំនួនរួមមាន :

- សំណើសុំបង្កើត និងតែងតាំងសមាសភាពដឹកនាំសាខា គណៈកម្មាធិការសាខា និងលើកសរសើរ ដាក់វិន័យចំពោះគណៈកម្មាធិការសាខា និងសមាសភាពដឹកនាំសាខាគណបក្ស ។

- សំណើសុំយោបល់អំពីការងារគណបក្សដែលមានការលំបាកស្មុគស្មាញ និងមិនទាន់ឯកភាពគ្នានៅក្នុងគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

- សំណូមពរផ្សេងៗរបស់សាខា អនុសាខា ក្រុមបក្ស និងសមាជិកគណបក្ស ព្រមទាំងសំណូមពររបស់មហាជន ប្រជាជន ដែលគណៈកម្មាធិការគណបក្សមូលដ្ឋានមិនអាចដោះស្រាយបាន ។

- សំណើសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេស ។

## II- <u>**រចនាសម្ព័ន្ធ អង្គការចាត់តាំងរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន**</u>

### ក- <u>**អំពីរចនាសម្ព័ន្ធ**</u> :

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សមូលដ្ឋានត្រូវមានមន្ត្រីគណបក្សដែលជាថ្នាក់ដឹកនាំសំខាន់ៗនៃអគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល មន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត គ្រឹះស្ថាន អង្គភាពនៅមូលដ្ឋាន និងមន្ត្រីសមាជិកគណបក្សទទួលបន្ទុកការងារគណបក្ស(ប្រធានក្រុមការងាររបស់គណបក្ស ប្រធានសាខាគណបក្ស)ដែលរួមមានមន្ត្រីវ័យចាស់ វ័យក្មេង ស្ត្រី និងមានសមត្ថភាពដឹកនាំ មានសុខភាពល្អ មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈគោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន ប្រជាជន និងមានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

ខ- **<u>អំពីបរិមាណ</u>** :

បរិមាណសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋាន រួមមានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក ត្រូវបានកំណត់ដូចខាងក្រោម :

- សមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋានមានចំនួន ២៧រូបចុះ ចំពោះគណៈកម្មាធិការគណបក្សដែលមានសាខាគណបក្សចំណុះចំនួន ១២ឡើងទៅ ។

- សមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋានមានចំនួន ២១រូបចុះ ចំពោះគណៈកម្មាធិការគណបក្សដែលមានសាខាគណបក្សចំណុះចំនួន ១១ចុះ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សមូលដ្ឋានរួមមានប្រធាន អនុប្រធាន ១រូប ឬ ២រូប និងសមាជិកអចិន្ត្រៃយ៍ ហើយមិនលើសពី ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋានទាំងមូល ។

គ- **<u>អំពីការដឹកនាំ គ្រប់គ្រងគណៈកម្មាធិការគណបក្សមូលដ្ឋាន</u>** :

ដើម្បីរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋានត្រូវមានលក្ខណសម្បត្តិ២យ៉ាងគឺ មានសមាជិកគណបក្សចាប់ពី ៥០នាក់ឡើងទៅ និងមានសាខាគណបក្សចំណុះចំនួន ៣ឡើងទៅ ។ នៅមូលដ្ឋានដែលមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវបង្កើតជាគណៈកម្មាធិការសាខាគណបក្ស ។

ការដឹកនាំ គ្រប់គ្រងគណៈកម្មាធិការគណបក្សមូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម :

- គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សក្រសួងដែលគ្រប់គ្រងគ្រឹះស្ថាននោះ ដោយសហការជាមួយគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សាឯកជន គ្រឹះស្ថានបណ្តុះបណ្តាលឯកជននៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សក្រសួងដែលទទួលខុសត្រូវតាមមុខជំនាញនីមួយៗ នៃគ្រឹះស្ថានសិក្សាទាំងនោះ ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនៅតាមខេត្ត ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សខេត្ត ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានវិទ្យាល័យ អនុវិទ្យាល័យ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។ គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អាចប្រគល់ភារកិច្ចដឹកនាំនេះឲ្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អនុវត្តជំនួសបាន ស្របតាមសភាពការណ៍ជាក់ស្តែង ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរពេទ្យធំៗនៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល ដោយសហការជាមួយគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរពេទ្យរបស់រាជធានី ខេត្ត ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។ គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អាចប្រគល់ភារកិច្ចដឹកនាំឲ្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អនុវត្តជំនួសបានស្របតាមសភាពការណ៍ជាក់ស្តែង ។

- គណៈម្មាធិការគណបក្សមូលដ្ឋានរោងចក្រ សហគ្រាស គ្រឹះស្ថាន អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម និងអង្គការសង្គមនានា ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។ គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អាចប្រគល់ភារកិច្ចដឹកនាំនេះឲ្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អនុវត្តជំនួសបានស្របតាមសភាពការណ៍ជាក់ស្តែង ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានអគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

ដោយឡែកចំពោះការរៀបចំគណៈកម្មាធិការគណបក្សមូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ៣៣ សណ.គក របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់ ។ ការរៀបចំគណៈកម្មាធិការគណបក្សមូលដ្ឋានរោងចក្រ សហគ្រាស ត្រូវអនុវត្តតាមសារាចរណែនាំលេខ ១១៨ សណ.គក

របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលស្តីពីការកសាងបក្ស កសាងអង្គការសហជីព និងចលនាកម្មករ និយោជិត តាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ។

**ឃ**- គណៈកម្មាធិការគណបក្សមូលដ្ឋាននីមួយៗត្រូវធ្វើការបែងចែកភារកិច្ចជូនសមាជិកម្នាក់ៗ ក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ឲ្យទទួលបន្ទុកដឹកនាំការងារគណបក្ស ជាអាទិ៍ការងារចាត់តាំង ការងារឃោសនាអប់រំ ការងារត្រួតពិនិត្យ ការងារហិរញ្ញវត្ថុ ការងារចលនាមហាជន និងទទួលបន្ទុកដឹកនាំការងារកសាងពង្រឹងតាមសាខាគណបក្សចំណុះ ស្របតាមសំណូមពរភារកិច្ចជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ។

**ង**- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រសួង ស្ថាប័ន ត្រូវផ្អែកលើគោលការណ៍កំណត់អំពីរចនាសម្ព័ន្ធ អង្គការចាត់តាំង និងផ្អែកលើលក្ខណៈពិសេសនៃមូលដ្ឋាន សំណូមពរការងារ និងលក្ខណសម្បត្តិរបស់មន្ត្រី សមាជិកគណបក្ស ដើម្បីសម្រេចបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន ដោយត្រូវធានាបាននូវនិរន្តរភាពការងារគណបក្ស ។

ចំពោះអង្គការចាត់តាំងគណបក្ស ដែលបានរៀបចំពីមុនមកខុសពីរចនាសម្ព័ន្ធកំណត់ ត្រូវពិនិត្យកែសម្រួល បំពេញបន្ថែម និងផ្ទេរអង្គការចាត់តាំងគណបក្ស ផ្ទេរជីវភាពសមាជិកគណបក្សឲ្យមកចំណុះក្រោមការដឹកនាំគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រសួង ស្ថាប័ន ស្របតាមគោលការណ៍កំណត់ថ្មីនេះ ។

## III- <u>**របៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន**</u>

- គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវប្រជុំជីវភាព១ខែម្តង គណៈអចិន្ត្រៃយ៍ប្រជុំ១ខែ២ដង ពេលចាំបាច់ត្រូវប្រជុំវិសាមញ្ញ ។ ក្រៅពីការប្រជុំជីវភាពប្រចាំខែ គណៈកម្មាធិការគណបក្សមូលដ្ឋានត្រូវកំណត់ពេលវេលា ១ដង ឬ២ដង ដើម្បីរៀនសូត្រឲ្យជ្រួតជ្រាបអំពីសភាពការណ៍ និងភារកិច្ចគណបក្ស ព្រមទាំងគោលការណ៍ សេចក្តីសម្រេចចិត្តនានារបស់គណបក្សថ្នាក់លើ ។

- គណៈកម្មាធិការគណបក្សមូលដ្ឋាន ដំណើរការមហាសន្និបាត១ឆ្នាំម្តង ដើម្បីត្រួតពិនិត្យការដឹកនាំគណបក្សក្នុងឆ្នាំកន្លងមក និងពិភាក្សាអនុម័តទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់ លើការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង ត្រួតពិនិត្យ ហិរញ្ញវត្ថុ ជីវភាព និងបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការគណបក្សមូលដ្ឋានថ្មី ។

- ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន កំណត់យកសម្លេងភាគច្រើនដាច់ខាតនៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល ឬគណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការងារមួយចំនួនដែលមានកំណត់ដោយឡែកក្នុងលក្ខន្តិកៈគណបក្ស ។

- ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវផ្អែកលើសេចក្តីសម្រេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន ដើម្បីដឹកនាំ ណែនាំ និងចាត់តាំងអនុវត្តនៅតាមផ្នែកការងារ និងសាខាគណបក្សចំណុះដែលខ្លួនទទួលខុសត្រូវ ។ ត្រូវមានរបបចុះជួយពង្រឹងគ្រប់សាខាគណបក្សចំណុះ និងស្វែងយល់សភាពការណ៍ ក្តាប់សំណូមពររបស់មន្ត្រីសមាជិកគណបក្ស និងមហាជន ប្រជាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សចេញសេចក្តីសម្រេចចិត្ត គោលការណ៍ និងវិធានការដឹកនាំរួម ។

- គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវអនុវត្តឲ្យបានទៀងទាត់នូវរបបរាយការណ៍ប្រចាំខែ អំពីសកម្មភាពការងាររបស់គណបក្សថ្នាក់ខ្លួន ជូនគណៈកម្មាធិការគណបក្សថ្នាក់លើ ។

ខុទ្ទកាល័យ គណៈចាត់តាំងគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**
លេខ..០៣២./ចត.គក
/១៩

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃចន្ទ ១៣រោចខែមាឃ ឆ្នាំចសំរឹទ្ធិស័កព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩

# ជំនួយស្មារតី
## សម្រាប់ដំណើរការរៀបចំបង្កើត
## គណៈកម្មាធិការគណបក្សមូលដ្ឋាននៃគ្រឹះស្ថានឧត្តមសិក្សា
## គ្រឹះស្ថានបណ្តុះបណ្តាល នៅរាជធានីភ្នំពេញ

យោង: -មាត្រាទី១៤ ជំពូក V នៃលក្ខន្តិកៈគណបក្ស
-ជំពូក IX នៃបទបញ្ជាផ្ទៃក្នុងគណបក្ស
-សេចក្តីណែនាំលេខ ០២/១៦ សណ.គក ចុះថ្ងៃទី ៦-៤-២០១៦ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន
-ទិសដៅការងារគណបក្សនៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ៤១
-សំណូមពរនៃការងារគ្រប់គ្រង កសាង ពង្រីកសមាជិកបក្ស ។

**គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល** សូមស្នើគណៈកម្មាធិការគណបក្សក្រសួង ជំរុញការអនុវត្តគោលការណ៍រៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាននៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ ដែលស្ថិតក្រោមឱវាទក្រសួង ដូចខាងក្រោម៖

**១**-អនុវត្តតាមគោលការណ៍ការងារកសាងបក្សមុននេះ គណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ បានជំរុញការកសាងពង្រីកសមាជិកបក្ស ក្នុងជួរនិស្សិត ដោយមានការចូលរួមរបស់អង្គការយុវជនមួយចំនួនរបស់គណបក្ស ហើយបានរៀបចំបង្កើតជាសាខាបក្សនិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ស្ថិតចំណុះក្រោមការដឹកនាំរបស់គណៈកម្មាធិការបក្សរាជធានីភ្នំពេញ។ ទន្ទឹមនេះគណបក្សក្រសួងក៏មានរៀបចំបង្កើតជាសាខាបក្សសាស្ត្រាចារ្យ បុគ្គលិក នៅតាមគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលដែលស្ថិតក្រោមឱវាទក្រសួង ។

២-គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល បានដាក់ចេញសេចក្តីណែនាំលេខ ០២/១៦ សណ.គក ចុះថ្ងៃទី ៦-៤-២០១៦ សំដៅជំរុញការរៀបចំអង្គការចាត់តាំងគណបក្សនៅតាមគ្រឹះស្ថានសិក្សា មន្ទីរពេទ្យ អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម រោងចក្រ សហគ្រាស អង្គការសង្គមនានា មន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត អគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួង ស្ថាប័ន ដើម្បីធានានូវតួនាទីដឹកនាំរបស់គណបក្ស សាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស និងការពង្រឹងពង្រីកសមាជិកបក្ស បង្កើនកម្លាំងគាំទ្រគណបក្ស ។ ដោយឡែក អំពីការដឹកនាំគ្រប់គ្រងគណៈកម្មាធិការគណបក្សមូលដ្ឋាន គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលបានលើកសំណើជូនអង្គសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៤០ នាថ្ងៃទី១៨-១២-២០១៦ អនុម័តកែប្រែចំណុចមួយចំនួនក្នុងប្រការ ២៥នៃបទបញ្ជាផ្ទៃក្នុងគណបក្ស ដើម្បីអនុវត្តឲ្យស្របតាមសំណូមពរការងារជាក់ស្តែងបច្ចុប្បន្ន ។

៣-ប្រការ២៥ នៃបទបញ្ជាផ្ទៃក្នុងគណបក្សបានកំណត់ជាគោលការណ៍ៈ

-គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សក្រសួងដែលគ្រប់គ្រងគ្រឹះស្ថាននោះ ដោយសហការជាមួយគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ។

-គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សាឯកជន គ្រឹះស្ថានបណ្តុះបណ្តាលឯកជននៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សដែលទទួលខុសត្រូវតាមមុខជំនាញនីមួយៗនៃគ្រឹះស្ថានសិក្សាទាំងនោះ ។

-គណៈកម្មាធិការគណបក្សមូលដ្ឋានគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនៅតាមខេត្ត ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សខេត្ត ។

៤-ដំណើរការរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន នៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាល រហូតបច្ចុប្បន្ននេះទើបបង្កើតបានជាគណៈកម្មាធិការសាខាបក្សនៅតាមគ្រឹះស្ថានរដ្ឋភាគច្រើន និងនៅតាមគ្រឹះស្ថានឯកជនតិចតួចប៉ុណ្ណោះ ។

៥-ស្នើគណៈកម្មាធិការគណបក្សក្រសួង ជំរុញដំណើរការរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាននៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលដែលស្ថិតក្រោមឱវាទក្រសួងឲ្យបានឆាប់ ដើម្បីបង្កលក្ខណសម្បត្តិដល់ការគ្រប់គ្រងកសាង ពង្រីកសមាជិកបក្ស និងកម្លាំងគាំទ្រគណបក្ស តាមជំហានការងារដូចខាងក្រោមៈ

**ទីមួយៈ** ត្រូវត្រួតពិនិត្យក្តាប់ស្ថិតិសាស្ត្រាចារ្យ បុគ្គលិក និស្សិតកំពុងសិក្សាតាមឆ្នាំនីមួយៗ និងចំនួនសមាជិកបក្សនៅតាមគ្រឹះស្ថាននីមួយៗ និងតាមសាខានៃគ្រឹះស្ថាននោះក្នុងរាជធានីភ្នំពេញ ។

**ទីពីរៈ** រៀបចំបង្កើតសាខាបក្សនៅកន្លែងដែលមានសមាជិកបក្ស ៣នាក់ឡើងទៅ។ ចំពោះសាខាបក្សដែលមានសមាជិកបក្សច្រើនត្រូវបង្កើតគណៈកម្មាធិការសាខាបក្ស ដែលមានចំនួន ១១រូបចុះ និងមិនលើស ១ភាគ៣ នៃចំនួនសរុបសមាជិកបក្សក្នុងសាខា ។

**ទីបីៈ** កសាងពង្រីកសមាជិកបក្សនៅតាមគ្រឹះស្ថានឲ្យបានចំនួន ៥០នាក់ឡើងទៅ និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាននៃគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាល ។ នៅកន្លែងដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺត្រូវពិនិត្យ រៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាបក្សចំណុះតែម្តង ។

**៦-អំពីវិធីដំណើរការៈ**

-ប្រធានគណៈកម្មាធិការគណបក្សក្រសួងដឹកនាំផ្ទាល់កិច្ចប្រជុំរួមជាមួយមន្ត្រីគណបក្សដែលជាសកលវិទ្យាធិការ ឬជាអ្នកដឹកនាំបង្គោលនៅតាមគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីផ្សព្វផ្សាយណែនាំអនុវត្តគោលការណ៍ ទិសដៅ ភារកិច្ច និងសំណូមពរនៃការរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន និងបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការគណបក្សក្រសួង និងមន្ត្រីជំនួយការចុះជួយការងារនេះ នៅតាមគ្រឹះស្ថាននីមួយៗដោយសហការជាមួយអង្គការយុវជនរបស់គណបក្សដែលធ្លាប់បានបំពេញភារកិច្ចការងារកសាង ពង្រីកសមាជិកបក្សក្នុងជួរនិស្សិតក្នុងរយៈពេលកន្លងមក ។

-មន្ត្រីគណបក្សដែលជាសកលវិទ្យាធិការ ឬជាអ្នកដឹកនាំបង្គោលនៅតាមគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលដឹកនាំកិច្ចប្រជុំរួមជាមួយសមាជិកបក្សដែលមានតួនាទីសំខាន់ៗផ្សេងទៀត ដើម្បីពិនិត្យវាយតម្លៃលក្ខណសម្បត្តិមន្ត្រី សមាជិកបក្សនៅក្នុងគ្រឹះស្ថានរបស់ខ្លួន ដើម្បីរៀបចំសំណើសុំបង្កើតសាខាបក្ស ឬគណៈកម្មាធិការសាខាបក្ស ឬគណៈកម្មាធិការគណបក្សមូលដ្ឋាន ដាក់ជូនគណៈកម្មាធិការគណបក្សក្រសួងពិនិត្យ និងសម្រេច ។ នៅកន្លែងដែលមានសាខាបក្សរួចហើយ ត្រូវប្រជុំគណៈកម្មាធិការសាខាបក្ស ដើម្បីពិនិត្យរៀបចំសំណើសុំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន នៅពេលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមគោលការណ៍កំណត់របស់គណបក្ស ។

-ការប្រជុំជីវភាព និងការងារគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រីសមាជិកបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែង និងអគាររបស់រដ្ឋ។

-ទម្រង់បែបបទក្នុងការស្នើរៀបចំបង្កើតសាខាបក្ស ឬគណៈកម្មាធិការគណបក្សមូលដ្ឋានដែលត្រូវដាក់ជូនគណៈកម្មាធិការគណបក្សក្រសួងពិនិត្យ រួមមានៈ

+សំណើរបស់អង្គប្រជុំដឹកនាំដោយមន្ត្រីគណបក្សដែលជាសកលវិទ្យាធិការ ឬជាអ្នកដឹកនាំបង្គោលនៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាល ឬសំណើរបស់គណៈកម្មាធិការសាខាបក្ស ។

+កំណត់ហេតុប្រជុំ

+បញ្ជីវត្តមានចូលរួមប្រជុំ

+ប្រវត្តិរូបមន្ត្រីដែលត្រូវបានស្នើសុំតែងតាំង មានបិទរូបថត។

-ក្រោយពេលសម្រេចបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋានរួចហើយ គណៈកម្មាធិការគណបក្សក្រសួងធ្វើសំណើតាមរយៈគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីរៀបចំបែបបទស្នើសុំក្រសួងមហាផ្ទៃផលិតត្រាគណៈកម្មាធិការគណបក្សមូលដ្ឋានផ្តល់ជូនសម្រាប់ប្រើប្រាស់ក្នុងការងារគណបក្ស ។

-គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល នឹងចាត់តាំងមន្ត្រីចូលរួមសហការក្នុងការងារខាងលើនេះតាមសំណូមពរការងារជាក់ស្តែងនៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលនានា និងគណៈកម្មាធិការគណបក្សក្រសួង។

៧-ព្រមជាមួយគ្នានេះ ស្នើគណៈកម្មាធិការគណបក្សក្រសួង ពិនិត្យផងដែរអំពីការរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន នៃអគ្គនាយកដ្ឋានចំណុះ និងថ្នាក់ប្រហាក់ប្រហែល ស្របតាមគោលការណ៍កំណត់របស់គណបក្ស។

ខ្លឹមសារដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** គណៈកម្មាធិការគណបក្សក្រសួង មេត្តាជំរុញដំណើរការរៀបចំបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាននៃគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាល ដែលស្ថិតក្រោមឱវាទក្រសួងឲ្យបានឆាប់ ហើយរាយការណ៍លទ្ធផលតាមរយៈគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីបូកសរុបរាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ក្នុងត្រីមាសទី២ ឆ្នាំ២០១៩នេះ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**